# តើអ្វីទៅជាការពិចារណាពិស្តារ ?

តើការពិចារណាពិស្តារ (critical thinking) មានន័យយ៉ាងដូចម្តេច?

ចំលើយអាចត្រូវបានរកឃើញនៅក្នុងព្រះពុទ្ធសាសនា ។ នៅពេលមួយព្រះពុទ្ធបានប្រាប់សិស្សរបស់ព្រះអង្គថាៈ

*"ពេលដែលអ្នកចង់ទិញមាសមួយដុំ អ្នកត្រូវ ឆែកឆេរ និងត្រួតពិនិត្យឱ្យបានហ្មត់ចត់ជាមុនសិន ។ អ្នកគួរធ្វើដូចគ្នា នៅពេលអ្នកធ្វើការរើកញែកលើដំបូន្មាន និងការបង្រៀនរបស់អាត្មា ។"*

នេះមានន័យថា គ្មានបុគ្គលណាម្នាក់ត្រូវបានបង្ខំឱ្យទទួលយក និងយល់ព្រមយក ការបង្រៀន ឬ ដំបូន្មានមួយ ក៏ព្រោះតែវាត្រូវបានផ្តល់ឱ្យដោយអាជ្ញាធរមួយនោះទេ ប៉ុន្តែមនុស្សម្នាក់ៗគួរតែពិនិត្យមើលអំពី ភាពត្រឹមត្រូវ និង ឧត្តមគតិរបស់ការបង្រៀន ឬដំបូន្មាននោះ ដោយខ្លួនឯង ប្រកបដោយការត្រិះរិះពិចារណាឈរលើគំនិតផ្ទាល់ខ្លួនផងដែរ ។ ដូច្នេះការពិចារណាពិស្តារមានន័យថា ជាការចោទជាសំនួរ ការលើកឡើងនូវការសង្ស័យ ការពិភាក្សា និង ការពិនិត្យលើគំនិតផ្សេងៗមុននឹងទទួលយកគំនិតទាំងនោះ ពីព្រោះថាដោយផ្អែកលើបទពិសោធន៍ យើងឃើញថា គ្មានមនុស្សណាម្នាក់ល្អឥតខ្ចោះនោះទេ ។

ហេតុដូច្នេះហើយ សៀវភៅនេះមិនត្រឹមតែមានបំណងជំរុញឱ្យអ្នកអានចេះវិភាគ ត្រិះរិះពិចារណា និងសាកសួរ អំពីពាក្យសំដីរបស់អាជ្ញាធរ មន្ត្រីរាជការ និងរបស់អ្នកធំប៉ុណ្ណោះទេ ប៉ុន្តែសៀវភៅនេះចង់ជំរុញផងដែរនូវការពិចារណា ពិស្តារលើអ្វីដែលបានសរសេរក្នុងសៀវភៅនេះ ។ មិត្តអ្នកអានគ្រប់រូប គួរតែគិតពិចារណាដោយផ្ទាល់អំពីភាពត្រឹមត្រូវ និងតំលៃនៃពត៌មាន និងដំបូន្មានដែលបានផ្តល់ឱ្យដោយសៀវភៅនេះលើបញ្ហាជាអាទិ៍ៈ ថាតើគំនិតទាំងអស់ដែលមាន នៅក្នុងសៀវភៅពិតជាអាចទទួលយកបាន និងសមស្របនឹងតថភាពជាក់ស្តែងនៃប្រទេសកម្ពុជាដែរឬទេ? តើអ្វីអាចនឹង ត្រូវបានផ្លាស់ប្តូរ ឬកែប្រែមុនពេលដែលព្រមគេទទួលយកនូវគំនិតទាំងនោះ?

ការដោះដូរយ៉ាងរស់រវើកនូវសំណើ និងគំនិតវិភាគទាំងឡាយ នឹងធ្វើឱ្យពុទ្ធដីការរបស់ព្រះពុទ្ធក្លាយជាការពិត ហើយដឹកនាំទៅរកប្រទេសកម្ពុជាមួយនៅពេលអនាគតដែលប្រកបទៅដោយមាសពិតៗ ។